# សុន្ទរកថាស្វាគមន៍
# របស់អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់
# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ថ្លែងក្នុងកម្មវិធីបើក
# នៃពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ដំណាក់កាលទី ៤ ៖ «គណនេយ្យ-ភាពសមិទ្ធកម្ម» នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថ្ងៃ ចន្ទ ១៤ រោច, ខែផល្គុន, ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣

- ខ្ញុំបាទសូមសម្តែងនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា !
- ខ្ញុំបាទសូមគោរព សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក-សមាជិកា នៃអង្គពិធីទាំងមូល !

ថ្ងៃនេះ, ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធា-រណៈ និង អង្គពិធីទាំងមូល, ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ និង ពេលដ៏មានតម្លៃបំផុត អញ្ជើញចូលរួមជាអធិបតី ក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ **ដំណាក់កាលទី ៤ ៖ «គណនេយ្យភាពសមិទ្ធកម្ម» នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ។ ជាមួយគ្នា, ខ្ញុំសូមសម្តែងនូវការស្វា-គមន៍យ៉ាងកក់ក្តៅបំផុត ជូនចំពោះ ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល និង មន្ត្រី-

រាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងតំណាងអង្គទូត និង ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានមកចូលរួមក្នុងពិធីដ៏មានសារៈសំខាន់នេះ ។

ក្នុងទិវាជាប្រវត្តិសាស្ត្រនេះ, ខ្ញុំបាទសូមអនុញ្ញាតគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជ្រាបដ៏ខ្ពង់ខ្ពស់ និង ជម្រាបជូនអង្គពិធី អំពីវឌ្ឍនភាពគន្លឹះក្នុងការអនុវត្តការងាររយៈកាលកន្លងមក និង ការត្រៀមបោះជំហានទៅកាន់ **ដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ដូចតទៅ ៖

ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ ៖ **ប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីប្រព័ន្ធផ្តោតលើធាតុចូល និង មានលក្ខណៈមជ្ឈការ ទៅជាប្រព័ន្ធ ដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និង មានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ ។** ដើម្បីសម្រេចចក្ខុវិស័យនេះ, យើងបានកំណត់យកយុទ្ធសាស្ត្របោះជំហានតាមដំណាក់កាល ឬ អភិក្រមជាខឿន តាមរយៈក្របខណ្ឌផែនការសកម្មភាពរួមដ៏លម្អិតមួយ ដែលផ្សំឡើងពី ៖ (១). បណ្តាសកម្មភាពចាំបាច់សម្រាប់ការកសាងមូលដ្ឋានគ្រឹះនៅតាមដំណាក់កាលនីមួយៗ; និង (២). សកម្មភាពចាំបាច់នានា ដែលត្រូវចាប់ផ្តើមសាកល្បងដកពិសោធន៍ជាបណ្តើរៗ មុនឈានចូលទៅដល់ដំណាក់កាលបន្ទាប់ ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ដំណាក់កាលទី ១ បានចាប់ផ្តើមឡើង នៅចុងឆ្នាំ ២០០៤ ដោយផ្តោតលើ «**ការពង្រឹងភាពជឿទុកចិត្តបាននៃថវិកា**» ហើយដែលត្រូវបានអនុវត្តរហូតដល់ឆ្នាំ ២០០៨ ដោយសម្រេចបាននូវសមិទ្ធ-ផលគន្លឹះជាមូលដ្ឋាន សម្រាប់ការបោះជំហានឡើងមកកាន់ដំណាក់កាលបន្ទាប់ នោះគឺ ៖ ការដោះស្រាយបានដោយជោគជ័យ នូវបញ្ហាបំណុលសាច់ប្រាក់ដ៏រ៉ាំរ៉ៃ; ការអនុវត្តពេញលេញនូវប្រព័ន្ធគណនីទោលរតនាគារជាតិ; ការធ្វើទំនើបកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធា-រណៈ; ការកែទម្រង់កិច្ចលទ្ធកម្មសាធារណៈ; ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ជាដើម ។ ទាំងអស់នេះ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ និង ជាបុរេលក្ខខណ្ឌ មិនអាចខ្វះបាន សម្រាប់ការ-ចាប់ផ្តើមដំណាក់កាលទី ២, ដោយផ្តោតលើ «**ការពង្រឹងគណនេយ្យភាពហិរញ្ញ-វត្ថុ**», ដែលត្រូវបានអនុវត្ត ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៥ ។ ដំណាក់កាលទី ២ នេះត្រូវបានអនុវត្តតាមរយៈក្របខណ្ឌផែនការសកម្មភាព រយៈពេល ៥ ឆ្នាំ, និងបន្ទាប់ពីបានឆ្លងការវាយតម្លៃ, ត្រូវបានបន្ថែមសកម្មភាពសម្រាប់អនុវត្ត រយៈពេលប្រមាណ ២ ឆ្នាំបន្តទៀត ដោយសម្រេចបាននូវសមិទ្ធផលជាសារវន្តមួយចំនួន ជាអាទិ៍ ៖ ការបើកផ្តល់បៀវត្សជូនមន្ត្រី

រាជការតាមប្រព័ន្ធធនាគារ; ការពង្រីកអង្គភាពសវនកម្មផ្ទៃក្នុង; ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS); និង ការចាប់ផ្តើមសាកល្បងអនុវត្តប្រព័ន្ធថវិកាកម្មវិធី នៅតាមក្រសួងមួយចំនួន ។

បន្ទាប់ពីបានវាយតម្លៃយ៉ាងម៉ត់ចត់លើវឌ្ឍនភាព រយៈពេល ៧ ឆ្នាំ នៃដំណាក់កាលទី ២ រួចមក, រាជរដ្ឋាភិបាលបានសម្រេចចាប់ផ្តើមអនុវត្តដំណាក់កាលទី ៣ ដែលជាដំណាក់កាលយុទ្ធសាស្ត្រដ៏សំខាន់មួយទៀត ដោយផ្តោតលើ «**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**» ។ ដំណាក់កាលទី ៣ នេះ ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ ២០១៦ មក ។ យ៉ាងណាមិញ, ដោយសារកត្តាសត្យានុម័តជាច្រើន, ជាពិសេស បញ្ហាវិបត្តិជំងឺកូវីដ-១៩, គោលដៅគន្លឹះមួយចំនួននៃដំណាក់កាលទី ៣ មិនអាចសម្រេចបានតាមកាលកំណត់ឡើយ ដែលជាហេតុតម្រូវឱ្យមានការពន្យារពេល តាមរយៈការដាក់ចេញនូវក្របខណ្ឌផែនការសកម្មភាពដំណាក់កាលទី ៣ នេះ ចំនួន ២ ឆ្នាំបន្ថែមទៀត, គឺ ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២២, មុននឹងយើងអាចចាប់ផ្តើមអនុវត្តដំណាក់កាលទី ៤ ដែលផ្តោតលើ «**គណនេយ្យភាពសមិទ្ធកម្ម**» នៅក្នុងឆ្នាំ ២០២៣ នេះ ។

បន្ថែមលើការពង្រឹងគណៈនេយ្យភាពហិរញ្ញវត្ថុ តាមរយៈការពង្រីក និង ការពង្រឹងការអនុវត្តថវិកាកម្មវិធី ក៏ដូចជាការកែលម្អ និង ការពង្រឹងប្រព័ន្ធគណនេយ្យសាធារណៈ និង ប្រព័ន្ធសវនកម្ម និង អធិការកិច្ចហិរញ្ញវត្ថុ, ពិសេស ការចាប់ផ្តើមដាក់ឱ្យអនុវត្តជាជំហានៗនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), លទ្ធផលជាក់ស្តែងជាសារវ័ន្តនៃការអនុវត្តដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈ ក៏រួមបញ្ចូលផងដែរ នូវយុទ្ធសាស្ត្រកែទម្រង់សំខាន់ៗ និង ច្បាប់គន្លឹះមួយចំនួនសម្រាប់ជាមូលដ្ឋានគ្រឹះនៃ **«ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម»** ជាអាទិ៍ ៖ យុទ្ធសាស្ត្រនៃការ-កែទម្រង់ប្រព័ន្ធថវិកា; យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ; យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម; យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធា-រណៈ; យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ; និង យុទ្ធ-សាស្ត្រកែទម្រង់ប្រព័ន្ធគណនេយ្យ ។ ថ្មីៗនេះ, **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)** ក៏ត្រូវបានអនុម័ត និង ប្រកាសដាក់ឱ្យប្រើប្រាស់ ជំនួស **ច្បាប់ស្តីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨** ដែលច្បាប់ថ្មីនេះ បានកំណត់ឱ្យរាជរដ្ឋាភិបាលរៀបចំដាក់ឱ្យ **«អនុវត្តជាមូល-ដ្ឋាន»** នូវ **«ថវិកាព័ត៌មានសមិទ្ធកម្ម»** ឱ្យបាន នៅឆ្នាំ ២០២៦ ។ បន្ថែមលើនេះ, **សេចក្តី-**

**ព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ** សម្រាប់ជំនួស **ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ ២០១២** និង **សេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធ** សម្រាប់ជំនួសច្បាប់ស្តីពីសារពើពន្ធជាធរមានបច្ចុប្បន្ន ក៏ត្រូវបានរៀបចំរួចស្រេចបាច់ផងដែរ ដែលរំពឹងថា នឹងអាចឆ្លងការពិនិត្យសម្រេចដោយអង្គគណរដ្ឋមន្ត្រី ព្រមទាំងការពិនិត្យ និង ការអនុម័ត ដោយស្ថាប័ននីតិបញ្ញត្តិ តាមនីតិវិធីច្បាប់ជាធរមាន ក្នុងពេលដ៏ឆាប់ខាងមុខ ។

- ***សម្តេចតេជោ នាយករដ្ឋមន្ត្រី, ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !***
- ***សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !***

សមិទ្ធផលក្នុងរយៈពេលជិត ២០ ឆ្នាំនេះ បានបង្ហាញជាក់ច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជា, ដែលមានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាសេនាធិការ, បាន និង កំពុង ធ្វើដំណើរនៅលើមាគ៌ាដ៏ត្រឹមត្រូវ ឆ្ពោះទៅកាន់ការសម្រេចបាន នូវចក្ខុវិស័យដែលបានកំណត់ ។ ជោគជ័យនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានផ្តល់ផលជាបណ្តើរៗ លើការពង្រឹងគុណភាព «**អភិបាលកិច្ចល្អ**» និង ការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរឹងមាំមួយ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចលើកកម្ពស់ជីវ-ភាព និង បម្រើសេវាសាធារណៈ ជូនប្រជាជនបានកាន់តែប្រសើរឡើង តាមរយៈការអភិវឌ្ឍធនធានមនុស្ស ឱ្យកាន់តែមានគុណភាព; ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានាដូចជា ប្រព័ន្ធគមនាគមន៍, ប្រព័ន្ធធារាសាស្ត្រ និង ប្រព័ន្ធអគ្គិសនី; ការកសាងសាលារៀន និង មន្ទីរពេទ្យ បានកាន់តែច្រើន និង មានគុណភាពកាន់តែប្រសើរឡើងឥតឈប់ឈរ ។ល។

សមិទ្ធផលជាប្រវត្តិសាស្ត្រនៃការកែទម្រង់ និង ការអភិវឌ្ឍ, ដែលយើងទាំងអស់គ្នាកំពុងតែក្រេបជញ្ជក់ជាមនុញ្ញផលនេះ, អាចសម្រេចបានមក ដោយសារកិច្ចប្រឹងប្រែងរួមជាធ្លុងមួយ ជាមួយនឹងឆន្ទៈមុត្រស្រួចឥតរាថយ នៃថ្នាក់ដឹកនាំ និង មន្ត្រីរាជការពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ នៃគ្រប់ក្រសួង-ស្ថាប័នជាតិ នៅក្រោមម្លប់ដ៏ត្រជាក់នៃ «**សន្តិភាព**» ដែល **អគ្គមហារដ្ឋបុរសដ៏ឆ្នើមគ្មានពីរ** នៃយើង គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាននាំមកជូនប្រទេសជាតិ និង ប្រជាជនកម្ពុជា តាមរយៈការតស៊ូលះបង់ដ៏ធំធេងបំផុត ពោលគឺ ដោយប្រថុយជីវិតផ្ទាល់ខ្លួន ដើម្បីបុព្វហេតុដ៏ឧត្តុងឧត្តមមិនអាចកាត់ថ្លៃបាននេះ ។ សមិទ្ធផល និង បទពិសោធន៍

ក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅ បានផ្តល់មេរៀនដ៏មានតម្លៃ ជាច្រើនអនេក និង បានធ្វើឱ្យយើងរឹតតែជឿជាក់លើភាពត្រឹមត្រូវនៃទស្សនៈវិស័យរបស់យើង នោះគឺ យើងត្រូវកែទម្រង់តាមសេចក្តីត្រូវការរបស់កម្ពុជា, ក្នុងបរិបទសង្គម-សេដ្ឋកិច្ច ស្ថាប័ន និង រដ្ឋបាល របស់កម្ពុជា, ក្នុងភាពជាម្ចាស់របស់កម្ពុជា, និង ជាពិសេស ក្នុងការទទួលខុសត្រូវរបស់កម្ពុជា ចំពោះជោគវាសនាអនាគតជាតិ ដោយខ្លួនឯង ស្របតាមបាវចនា ២ ៖ «**កែទម្រង់ខាងក្នុង**, **បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ**»; និង អភិក្រមទាំង ៥ ៖ «**ឆ្លុះកញ្ចក់**, **ងូតទឹក**, **ដុសក្អែល**, **ព្យាបាល និង វះកាត់**»; របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ។

**កែទម្រង់-រស់**, **មិនកែទម្រង់-ស្លាប់**! នេះ គឺជាឱវាទានុសាសន៍ដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការ-គ្រប់គ្រងហិរញ្ញត្ថុសាធារណៈ តែងប្រកាន់ខ្ជាប់ ជាប្រទីបនាំផ្លូវ នៅក្នុងគ្រប់សកម្មភាពរបស់ខ្លួន ។ ឱវាទានុសាសន៍នេះ តែងក្រើនរំលឹក និង ដាស់ស្មារតីយើងទាំងអស់គ្នាជាប់ជាប្រចាំថា យើងគ្មានជម្រើសអ្វីល្អជាង ក្រៅពីត្រូវកែទម្រង់នោះឡើយ, កែឱ្យបានល្អ, កែឱ្យកាន់តែមានប្រសិទ្ធភាព និង កែឱ្យបានរីកចម្រើនរុងរឿងថែមទៀត! ប្រាកដណាស់ថា ការកែទម្រង់ជាការងារដ៏លំបាកស្មុគស្មាញ, ដោយម្ខាង, យើងត្រូវជួបប្រទះបញ្ហាប្រឈមច្រើន, ទាំងផ្នែកផ្នត់គំនិត, ឆន្ទៈ, ភាពជាអ្នកដឹកនាំ, ការប៉ះពាល់ផលប្រយោជន៍, សមត្ថភាព, ធនធានមនុស្ស និង បញ្ហាបច្ចេកទេស; និង ម្ខាងទៀត, យើងត្រូវតែចាប់ផ្តើមធ្វើ ដោយមិនបង្អង់រង់ចាំទាល់តែមានសមត្ថភាព, ធនធាន និង មធ្យោបាយគ្រប់គ្រាន់នោះឡើយ ក្នុងស្មារតី «**ធ្វើបណ្តើរ**, **រៀនបណ្តើរ**, **និង កែលម្អបណ្តើរ**» ។ ដូច្នេះ, ការកែទម្រង់ អាចប្រៀបប្រដូចបានទៅនឹងការដាំ និង ការថែរក្សាដើមឈើយ៉ាងដូច្នោះដែរ ដែលតម្រូវឱ្យមានភាពអត់ធ្មត់ និង ទ្រាំជម្នះភាពនឿយហត់, ហើយជួនកាលរួមទាំងភាពជូរចត់ផងដែរ; ក៏ប៉ុន្តែ, ផ្លែផ្កាដែលទទួលបានពីកិច្ចខិតខំប្រឹងប្រែងដ៏មោះមុត និង ការព្យាយាមឥតរាថយនោះ គឺ ៖ ភាពរីករាយ, ក្តីសុខក្សេមក្សាន្ត និង ការរីកចម្រើនឈានឡើងជាបន្តបន្ទាប់ របស់សង្គមជាតិប្រកបដោយវិបុលភាព និង ចីរភាព ។

ពេលនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានដល់ដំណាក់-កាលទី ៤ ៖ «**គណនេយ្យភាពសមិទ្ធកម្ម**» ដែលជាដំណាក់កាលចុងក្រោយរបស់ខ្លួន ដោយសម្រួចទិស និង តម្រង់គោលដៅ ឆ្ពោះទៅរក «**សមិទ្ធកម្ម ឬ លទ្ធផល**» ។ ក្នុងន័យនេះ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ ពិតជាត្រូវ-

ការ នូវការគាំទ្រ ក៏ដូចជាការចូលរួមកាន់តែសកម្មឡើងថែមទៀត ពីសំណាក់គ្រប់ដៃគូ និង តួ-អង្គពាក់ព័ន្ធទាំងអស់, ជាពិសេស ពីសំណាក់គ្រប់ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីសម្រេចឱ្យបានជោគជ័យនូវផែនការសកម្មភាពទាំងឡាយនៅក្នុង **ដំណាក់កាលទី ៤** នេះ ដែលខ្ញុំសូមអនុញ្ញាតគូសរំលេចនូវការងារជាអាទិភាពគន្លឹះមួយចំនួន ដូចខាងក្រោម ៖

**ទី១).** ការរៀបចំជំរុញអនុវត្តនូវ **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣** ដែលទើបត្រូវបានត្រូវបានអនុម័ត ដាក់ឱ្យប្រើជំនួស **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨** ។

**ទី២).** ការរៀបចំជំរុញអនុវត្តនូវ **ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម** និង **ក្របខណ្ឌថវិការយៈពេលមធ្យម** ។

**ទី៣).** ការពង្រឹង និង ការជំរុញការអនុវត្តយុទ្ធសាស្ត្រកែទម្រង់សំខាន់ៗ ដែលត្រូវបានដាក់ចេញរួចហើយ ដើម្បីបន្តផ្តល់ការគាំទ្រ និង មូលដ្ឋានគ្រឹះរឹងមាំ ដល់ការអនុវត្តកម្មវិធីកែទម្រង់របស់យើងទៅមុខទៀត ដែលរួមមានជាអាទិ៍ ៖ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា; យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ; យុទ្ធសាស្ត្រគៀរគរចំណូល; យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ; យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់-គ្រងការវិនិយោគសាធារណៈ និង យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគណនេយ្យ ។

**ទី៤).** ការផ្តោតអាទិភាពលើ «**សមិទ្ធកម្ម**» ជាមូលដ្ឋានគ្រឹះក្នុងការរចនា និង អនុ-ម័តថវិកាកម្មវិធី ប្រចាំឆ្នាំ ។ និង

**ទី៥).** ការពង្រីកវិសាលភាព និងការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

- ***សម្តេចតេជោ នាយករដ្ឋមន្ត្រី, ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !***
- ***សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !***

មុននឹងបញ្ចប់, ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ្ញុំសូមសម្ដែងនូវកតញ្ញូតាធម៌ និង កតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុត គោរពជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចំពោះឧបការគុណដ៏ខ្ពង់ខ្ពស់បំផុត នៅក្នុងការដឹកនាំ, ការចង្អុលបង្ហាញ និង ការគាំទ្រ ក្នុងគ្រប់កាលៈទេសៈ, ជាពិសេស នៅពេលមានបញ្ហាវិបត្តិស្មុគស្មាញផ្សេងៗ ដូចជា វិបត្តិនៃជំងឺកូវីដ-១៩ ថ្មីៗនេះ ដែលទាមទារនូវការសម្រេចចិត្ត និង ការដឹកនាំ-បញ្ជា ប្រកបដោយគតិបណ្ឌិត, ភាពឈ្លាសវៃ, យុត្តិធម៌ និង គុណធម៌, ជាបច្ច័យនាំឱ្យសម្រេចបាននូវសមិទ្ធផលជាប្រវត្តិសាស្ត្រ នៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ ក៏ដូចជាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំថ្ងៃ ក្នុងរយៈពេល ២ ទសវត្សរ៍កន្លងទៅ ។

ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដល់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់, ជាពិសេស សមាសភាពនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ននានា ដែលបានចូលរួមអនុវត្តផែនការសកម្មភាពកែទម្រង់ យ៉ាងសស្រាក់សស្រាំ តាំងពីក្នុងដំណាក់កាលទី ១ រហូតមកដល់ដំណាក់កាលទី ៤ ដែលជាដំណាក់កាលចុងក្រោយនេះ ។ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅផងដែរ ជូនបណ្ដាដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានផ្ដល់នូវកិច្ចសហការ និង ការឧបត្ថម្ភគាំទ្រ, ទាំងផ្នែកបច្ចេកទេស និង ផ្នែកហិរញ្ញវត្ថុ, សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគោរពខ្ជាប់ខ្ជួន នូវភាពជាម្ចាស់របស់កម្ពុជា ។ ចុងក្រោយ, ខ្ញុំសូមវាយតម្លៃខ្ពស់ និង កោតសរសើរ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រី-បុគ្គលិកនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកន្លងមក បានបំពេញការងារជាសេនាធិការយ៉ាងល្អ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ជាមួយនឹងការឧទ្ទិសខ្លួនចំពោះការងារកែទម្រង់ ។

ខ្ញុំរំពឹងថា ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព និង ស្ថិរភាព គួបផ្សំនឹងការរួមគ្នាជាធ្លុងមួយ ឧទ្ទិសនូវកម្លាំងកាយ ប្រាជ្ញា និង ស្មារតី ក្នុងឆន្ទៈមោះមុតឥតរាថយ ចំពោះកិច្ចការកែទម្រង់, យើងនឹងទទួលបានជោគជ័យថ្មីៗថែមទៀត ក្នុងការអនុវត្តដំណាក់កាលទី ៤ នេះ ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យនៃការប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យឆ្លើយតបទៅតាមស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ ដែល

ជាសមាសភាគដ៏សំខាន់មួយ សម្រាប់ការធានានូវវឌ្ឍនភាពជាតិ តាមបង្គោលចរ ឆ្នាំ ២០៣០ និង ឆ្នាំ ២០៥០ ។

ក្នុងស្មារតីនេះ, យើងទាំងអស់គ្នាទន្ទឹងរង់ចាំត្រងត្រាប់ដោយយកចិត្តទុកដាក់បំផុត នូវការផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់ជាប្រយោជន៍ដល់ការជំរុញអនុវត្ត ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវកិច្ចការកែទម្រង់ដ៏មានសារៈសំខាន់មួយនេះ ។

***សូមអរគុណ !***